# សូមអ្នកជួយ . . .

ទុក្ខហើយនិងសុខមិនឆ្ងាយគ្នា　　មានក្ររងាក្នុងជីវិត
វាសនាចារមកដាក់កំហិត　　តើអ្នកមានចិត្តយល់យ៉ាងណា?

វាសនានាំមកជាកូនខ្មែរ　　ទោះមិនស្គាល់ស្រែគួរស្គាល់ជាតិ
ត្រូវតែខំប្រឹងនិងខំឆ្លៀត　　អោយសមទាយាទកើ្ដដំណែល ។

ជីវិតនាំមកនៅស្រុកគេ　　ចំនេះចំនេរមានគ្រប់បែប
តែយើងកុំភ្លេចនៅចំណែក　　ដែលវាជាផ្នែកវប្បធម៌ខ្មែរ ។

ទំនៀមទំលាប់ប្រពៃណី　　យើងគួរលកលៃថែរក្សា
ពូជពង្សជាតិខ្មែរពីដូនតា　　គួរតែមេត្តាថែមរតក ។

ខ្មែរអើយកូនខ្មែរកុំភ្លេចគ្នា　　គួរជួយការពារនិងឧបត្ថម្ភ
អោយហើយនិងយកកុំច្រលំ　　ជាពាក្យពីរផ្សំន័យខុសគ្នា ។

បងប្អូនខ្មែរអើយគួរថ្លឹងថ្លែង　　ដូចព្រះសំដែងហើយបានចារ
សទ្ធាជាស្ពានអោយជ្រះថ្លា　　មេត្តាករុណាសែនប្រពៃ ។

បើអ្នកមានហើយគួរផ្តល់ទាន　　ដល់អ្នកអត់ឃ្លានកំសត់ក្រ
ពេលខ្លះមិនមានបាយអង្ករ　　សាច់ត្រីមាន់ល្អជាអាហារ ។

ជីវិតទុគ៌តដូចរងបាប　　ផ្ទះដូចខ្យល់ខាបគ្មានដំបូល
ពេលយប់យន់ស្វាត់លឺក្អែកបូល　　គួរអោយអាសូរជីវិតណាស់ ។

បើយើងទឹកឃើញគួររំលែក　　អោយហើយនិងចែកច្រើនតិចក្តី
មិនប្រកាន់ថាប្រុសឬស្រី　　គួរតែរកលៃផ្គត់ផ្គង់គ្នា ។

តើជនម្នាក់ណាមិនចង់មាន　　ជៀសផុតអត់ឃ្លានក្រៀមរងា
កុំអោយជំងឺមកបៀតបៀរ　　ចង់សុខរម្យនាដូចគេឯង ។

ជំនួយលោកអ្នកសែនធំក្រៃ　　មិនអាចតថ្លៃទឹកចិត្តល្អ
អ្នកអត់អ្នកក្រសែនត្រេកអរ　　ជូនបុណ្យបវរដល់អ្នកថ្លៃ ។

Little Monkey
November 2006